# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0081**

## សម្ភាសន៍ជាមួយឈ្មោះ ឈុំ ភួត ភេទប្រុស អាយុ៥៣ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម“យោធា”

## រស់នៅផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៣៤:៤៨

**១៣ទំព័រ**

វណ្ណៈ: ចឹងមុនហ្នឹងសម្ភាសន៍ពូខ្ញុំសូមណែនាំខ្លួនថាខ្ញុំមកពីខាងណា?

ភួតៈ: បាទ ។

វណ្ណៈ: ខ្ញុំឈ្មោះសុខ វណ្ណៈមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ភួតៈ: បាទ ។

វណ្ណៈ: ហើយខ្ញុំបានមកដល់ស្រុកភូមិនេះដោយសារខ្ញុំចង់សរសេររឿងរ៉ាវដែលទាក់ទងនិងប្រវត្តិសាស្រ្តដែលបងប្អូនយើងធ្លាប់ឆ្លងកាត់ដូចជាជំនាន់ពូហ្នឹង ធ្លាប់ឆ្លងកាត់រឿងរ៉ាវអីខ្លះ?

ភួតៈ: បាទ ។

វណ្ណៈ: ចឹងយើងមិនបាននិយាយចេញមកទេ ថ្ងៃក្រោយយើងស្លាប់បាត់ទៅយើងកប់ប្រវត្តិសាស្រ្តនិងចោល ។

ភួតៈ: បាទ ។

វណ្ណៈ: ចឹងយើងចង់បានអ្នកដែលបានដឹងរឿងរ៉ាវនិយាយប្រាប់មកយើងចងក្រងជាឯកសារទុកឲ្យក្មេងជំនាន់ក្រោយបានដឹង បើយើងនិយាយតៗតែមាត់ទេ អាចក្មេងៗមិនជឿ ។

ភួតៈ: បាទ ។

វណ្ណៈ: ហើយបន្តិចទៀតក្រសួងនិងរៀបចំកម្មវិធីឲ្យក្មេងរៀនតាមសាលារឿងទាក់ទងនិងប្រវត្តិសាស្រ្តយើងហ្នឹង តាមពិតយើងត្រូវតែរៀនឲ្យដឹងថាប្រទេសយើងជួបការលំបាកយ៉ាងម៉េច បានសុខស្រួលយ៉ាងម៉េច?

ភួតៈ: បាទ ។

វណ្ណៈ: ចឹងការសម្ភាសន៍ខ្ញុំជាមួយពូ តើពូអនុញ្ញាតឲ្យខ្ញុំយកទៅប្រើការបានទេ?

ភួតៈ: បាន ។

វណ្ណៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ តើពូឈ្មោះអីទៅ?

ភួត៖ ខ្ញុំឈ្មោះ ឈុំ ភួតនិងឈ្មោះនៅក្នុងបញ្ជីរជាតិ ។

វណ្ណៈ ចឹងពូមានអាយុប៉ុន្មានហើយ?

ភួត៖ ខ្ញុំអាយុ៥៣ឆ្នាំហើយ ។

វណ្ណៈ ប្រពន្ធពូឈ្មោះអីដែរ?

ភួត៖ ឈ្មោះ ពិន វ៉ាន ។

វណ្ណៈ គាត់អាយុប៉ុន្មានហើយ?

ភួត៖ អាយុ៥២ ។

វណ្ណៈ ពូមានកូនប៉ុន្មាននាក់?

ភួត៖ ខ្ញុំមានកូន៥នាក់ ។

វណ្ណៈ ស្រីប៉ុន្មាន?

ភួត៖ ស្រី២ប្រុស៣ ។

វណ្ណៈ ឪពុករបស់ពូឈ្មោះអីដែរ?

ភួត៖ ឈ្មោះ ឈុំ ដែង ។

វណ្ណៈ ម្តាយ?

ភួត៖ ម្តាយ ក្រាម យាន ។

វណ្ណៈ ចឹងគាត់រាល់ថ្ងៃនៅរស់ដែរ?

ភួត៖ គាត់ស្លាប់យូរហើយ ។

វណ្ណៈ គាត់ស្លាប់ក្រោយ៧៩?

ភួត៖ ម្តាយខ្ញុំស្លាប់តាំងពីខ្ញុំនៅតូច តែឪពុកខ្ញុំស្លាប់នៅឆ្នាំ១៩៨៦ កាលដែលខ្ញុំទៅរៀននៅម៉ាឡេស៊ី ។

វណ្ណៈ ចឹងស្រុកកំណើតពូពិតប្រាកដនៅណា?

ភួត៖ ខ្ញុំនៅភូមិផ្ដាំហ្នឹងឯង ។

វណ្ណៈ ឃុំ?

ភួត៖ ឃុំផ្ដាំ កាលនោះស្រុកថ្មពួក កាលនោះខេត្តបាត់ដំបង ។

វណ្ណៈ ចឹងឥឡូវនៅភូមិ?

ភូតៈ នៅភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។ គ្រួសារខ្ញុំទេជាអ្នកខេត្តសៀមរាប ។

វណ្ណៈ ចឹងកាលពីតូចពូរៀននៅណា?

ភូតៈ កាលពីតូចខ្ញុំរៀននៅសាលាបឋមសិក្សាផ្គាំហ្នឹងឯង តែខ្ញុំរៀននៅវត្តផងខ្ញុំរៀននៅសាលានេះផង ។

វណ្ណៈ កាលហ្នឹងរៀនបានថ្នាក់ទីប៉ុន្មាន?

ភូតៈ កាលហ្នឹងរៀនបានថ្នាក់ទី៨"ចាស់" ជំនាន់រាស្ត្រនិយម ។

វណ្ណៈ ខ្ញុំឈប់រៀននៅឆ្នាំណា?

ភូតៈ ខ្ញុំឈប់រៀននៅឆ្នាំ៧៤ ។

វណ្ណៈ ចឹងកាលឆ្នាំរដ្ឋប្រហារនៅរៀនបានភូមិនេះ?

ភូតៈ បាទ!ឆ្នាំ៧៤បានខ្មែរក្រហមវាំរំដោះភូមិនេះចេញ កាលឆ្នាំ៧៤ខែ៨ ។

វណ្ណៈ ចឹងពូបានរៀនរហូតដល់ឆ្នាំ៧៤?

ភូតៈ បាទ ។

វណ្ណៈ ចឹងកាលឆ្នាំ៧៤នៅពេលដែលឈប់រៀនទៅធ្វើអីណា?

ភូតៈ ខ្មែរក្រហមគេជម្លៀសប្រជាជនចេញពីភូមិទៅ ចេញទៅខាងស្រុកស្រីស្នំនោះ ។

វណ្ណៈ ស្រុកស្រីស្នំ?

ភូតៈ បាទ!ស្រីស្នំខេត្តសៀមរាប ។

វណ្ណៈ នៅរហូតដល់ពេលណា?

ភូតៈ នៅរហូតដល់ឆ្នាំ៧៥ ខែ៣គេរើសឲ្យចូលទ័ពខ្មែរក្រហមហ្នឹង ។

វណ្ណៈ ទ័ពខ្មែរក្រហមពូឈរជើងនៅណា?

ភូតៈ ខ្ញុំឈរជើងនៅតំបន់ហ្នឹងឯងវរៈ៤១៥ នៅម្តុំថ្មពួកហ្នឹងឯង ។

វណ្ណៈ ជិតទល់ដែនសៀម?

ភូតៈ មិនមែនទេ កាលនោះមិនទាន់វាំរំដោះពីខាងលន់ នល់បានទេ ។

វណ្ណៈ ៧៥បែកហើយ?

ភូតៈ ៧៥ថ្ងៃទី១៧ មេសាបានរំដោះបាន ។

វណ្ណៈ អូ!៧៥ខែ៣ កាលចូល?

ភូតៈ បាទ!៧៥ខែ៣ ។

វណ្ណៈ	ចឹងកាលហ្នឹងវេជាមួយទាហានលន់ នល់?

ភួតៈ	បាទ ។

វណ្ណៈ	ចឹងកាលហ្នឹងខាងទាហានខ្មែរក្រហមនិងទាហានលន់ នល់ស្លាប់ច្រើនទេ?

ភួតៈ	ស្លាប់ច្រើនដែរ វេមុំថ្មពួក ស្វាយចេកអីនេះ ។

វណ្ណៈ	ចឹងកាលហ្នឹងវេជាមួយលន់ នល់?

ភួតៈ	បាទ ។

វណ្ណៈ	ចឹងដល់ថ្ងៃទី១៧មេសាឆ្នាំ៧៥?

ភួតៈ	១៧មេសា ខ្ញុំនៅប្រចាំការនៅផ្សារតាមាន់ ឆ្លកនេះឯង ភូមិឆ្លក រំដួលស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ។

វណ្ណៈ	ចឹងប្រចាំការហ្នឹងរហូតធ្វើអីខ្លះ?

ភួតៈ	ខ្ញុំប្រចាំការនៅជាយដែន ដល់ឆ្នាំ៧៧បានខ្ញុំទៅខាងព្រំដែនសំឡូតខាងចក្រីវិញ ឆ្នាំ៧៧ខែ ៨ ។

វណ្ណៈ	ការពារព្រំដែន?

ភួតៈ	ការពារព្រំដែនមិនដែលឃើញអ្នកស្រុកអីយ៉ាងណាផង ។

វណ្ណៈ	ចឹងកាលហ្នឹងមានព្រៃច្រើនទេ?

ភួតៈ	កាលហ្នឹងសម្បូរព្រៃណាស់ ចូលមិនចុះទេមុំម៉កហ៊ឹនអីហ្នឹង មានតែតាមថ្នល់បារាំងបន្តិចៗ ហ្នឹងឯង ។

វណ្ណៈ	ចឹងយើងការពារខ្មាចថៃវាចូលមក?

ភួតៈ	ការពារខាងថៃផង ការពារខ្មាចប្រជាពលរដ្ឋរត់លួនចេញទៅថៃទៅអី ។

វណ្ណៈ	មានដែលចាប់ប្រជាជនបានទេ?

ភួតៈ	ខាងខ្ញុំនោះមិនសូវជាចាប់ប្រជាជនបានប៉ុន្មានទេ តែក្នុងកងខ្ញុំមិនសូវបានទេ តែកងគេដទៃ ចាប់បាន ព្រោះកាលនោះតំបន់ព្រៃស្តុក គេមិនសូវរត់ទៅខាងនោះទេ គេច្រើនរត់ទៅ ប៉ែកខាងជើង ។

វណ្ណៈ	ចឹងនៅពេលដែលយោធាខ្មែរក្រហមចាប់បានបញ្ជូនមកក្រោយវិញឬមួយយ៉ាងម៉េច?

ភួតៈ	រឿងដែលចាប់បានហ្នឹងខ្ញុំមិនសូវដឹងថាបញ្ជូនឬយ៉ាងម៉េចទេ តែឲ្យតែចាប់បានបញ្ជូនមក ស្នាក់ការកងពលគេ ។

វណ្ណៈ	ចឹងមានយោធាខ្មែរក្រហមខ្លះឃើញប្រជាជនហើយអាណិត ឲ្យរត់ចេញឲ្យផុតតែម្ដងមានទេ?

ភូតៈ	មានដូចជាមេកងខ្ញុំឈ្មោះ យឿន យ៉ុនហ្នឹងកាលពីឆ្នាំ៧៧តែខ្ញុំភ្លេចខែ ។

វណ្ណៈ	កាលហ្នឹងយឿន យ៉ុនគាត់មានឋានៈអីដែរ?

ភូតៈ	គាត់មានឋានៈកងធំ ពីដើមគេហៅកងអនុសេនាធំមេខ្ញុំហ្នឹង ។

វណ្ណៈ	ចឹងមានឲ្យប្រជាជនរត់ដែរ?

ភូតៈ	បាទ! កាលហ្នឹងចាប់បានប្រជាពលរដ្ឋទទួលគាត់នៅម្ដុំសាយសាម៉ន កាលហ្នឹងប៉ះចំបងប្អូនគាត់ដឹង ដល់នេះគាត់បណ្ដោះរត់ទៅទាំងយឿន យ៉ុនទាំងប្រជាពលរដ្ឋជាង២៥នាក់ ។

វណ្ណៈ	ចឹងយឿន យ៉ុនហ្នឹងក៏ចេញទៅដែរ?

ភូតៈ	បាទ!គាត់នាំប្រជាពលរដ្ឋរត់ចេញទៅ ។

វណ្ណៈ	ចឹងកាលហ្នឹងមានចាប់បានយឿន យ៉ុនទេ?

ភូតៈ	អត់មានចាប់បានទេ ។

វណ្ណៈ	ចេញទៅបាត់ខ្លួនរហូត?

ភូតៈ	អត់ទេ កាលខ្ញុំមកធ្វើប៉ារាជួបគ្នា តែក្រោយមកគាត់ស្លាប់នៅខាងអូរស្មាច់កាលហ្នឹងគាត់

នាំពួកហ្នឹងបាស់បោលធ្វើជាចលនាសេរីការទប់ទល់និងពួកខ្មែរក្រហមវិញ ។

វណ្ណៈ	ចឹងអគ្គភាពពូការពារនៅខាងចក្រីសំឡូតហ្នឹងមានគ្នាប៉ុន្មានរយនាក់ដែរ?

ភូតៈ	ខ្ញុំកាលនោះមិនសូវក្ដាប់បានដែរ កាលនោះខ្ញុំនៅវ័យក្មេងដែរ ខ្ញុំដឹងថាមួយវរៈសេនាតូចចឹងមានគ្នា៣៦០នាក់ គឺពេញតែម្ដងមិនដែលខ្វះដូចជាសម័យបច្ចុប្បន្នទេ ។

វណ្ណៈ	ចឹងវរៈសេនាធំមានប៉ុន្មានទៅ?

ភូតៈ	មួយវរៈសេនាធំវាមានបីកងវរៈសេនាតូច

យើងគុណតាមហ្នឹងទៅឃើញហើយកាលជំនាន់ ហ្នឹងមិនដែលមានខ្វះទេ ។

វណ្ណៈ	ចឹងបីវរៈសេនាធំស្មើមួយកងពលទៀត?

ភូតៈ	បាទ ។

វណ្ណៈ	ចឹងប្រធានវរៈរបស់ពូពីណាគេ អះ!ប្រធានកងពល?

ភូតៈ	ប្រធានកងពលឈ្មោះ លោក សាវ៉ែងហ្នឹងឯង តែគាត់គេចាប់សម្លាប់ចោលអស់ហើយកាលហ្នឹង ។

វណ្ណៈ ចឹងគេចាប់ខ្លួនគាត់?

ភួតៈ បាទ!គេចាប់ខ្លួនកាលសម័យឆ្នាំ៧៧ ខែ១០ហ្នឹងឯង ។

វណ្ណៈ ចឹងមានពីណាចូលមកជំនួស?

ភួតៈ ចូលមកជំនួសមានស្មឹងហ៊ុនទេ ឈ្មោះ ហ៊ុនមួយនិងភាព ។

វណ្ណៈ ចឹងកាលហ្នឹងពូនៅកងទ័ពហូបចុកធម្មតា?

ភួតៈ បាទ!កងទ័ពហូបចុកធម្មតាមិនអីទេ ។

វណ្ណៈ តែកាលហ្នឹងពូមានដែលមកលេងផ្ទះទេ?

ភួតៈ មិនដែលបានមកលេងទេ ។

វណ្ណៈ ចឹងអត់មានសុំគេមកលេងទេ?

ភួតៈ សុំមិនដែលបានទេ គេមិនឲ្យមកឃើញប្រជាពលរដ្ឋវេទនាតែម្ដង ។

វណ្ណៈ ចឹងពូមានដឹងថានៅខាងក្រោយវេទនាទេ?

ភួតៈ ខ្ញុំមិនបានដឹងទេ ។

វណ្ណៈ ចឹងមិនបានដឹងប្រជាជនពិបាកទេ?

ភួតៈ អត់ទេ ។

វណ្ណៈ ចឹងនៅកន្លែងពូមានអង្គការចាប់ខ្លួនដែរ?

ភួតៈ មានកាលមុនដំបូងចាប់កងពល ក្រោយមកចាប់វរៈសេនាធំ រហូតដល់អនុសេនាធំ ។

វណ្ណៈ កាលហ្នឹងមានដឹងថាចាប់យកទៅណាទេ?

ភួតៈ មិនបានដឹងថាយកទៅណាទេ ។

វណ្ណៈ ចឹងកាលឆ្នាំ៧៧-៧៨ នៅពេលដែលកងទ័ពខ្មែរក្រហមជាប់ដៃវៃជាមួយកងទ័ពវៀតណាមនៅខាងស្វាយរៀង ចឹងគេមានមកដកកំលាំងពីខាងពូឲ្យទៅជួយទេ?

ភួតៈ បាទ!មានដកកាលហ្នឹង ។

វណ្ណៈ ចឹងពូមានបានទៅទេ?

ភួតៈ ទៅបានរយៈពេលពីរខែ ។

វណ្ណៈ ចឹងពូទៅឆ្នាំណា?

ភួតៈ ខ្ញុំទៅកាលឆ្នាំ៧៨ ។

វណ្ណៈ ចឹងប្រហែលជាខែណា?

ភួតៈ ៧៨ប្រហែលជាខែ៩ហ្នឹងឯង ខ្ញុំទៅដល់ខាងតាកែវហ្នឹងឯង ។

វណ្ណៈ ចឹងទៅដល់បានប្រហែលពីរខែទៀតណាមវៃមកវិញ?

ភួតៈ បាទ ។

វណ្ណៈ ចឹងពេលដែលវៃមកវិញរត់បណ្តោយ?

ភួតៈ បាទ!រត់បណ្តោយ កាលខ្ញុំទៅនៅម៉ុបុរីដល់សា ។

វណ្ណៈ ចឹងនៅឆ្នាំ១៩៧៩រត់មកខាងព្រំដែនវិញ?

ភួតៈ បាទ!ខ្ញុំរត់កាត់តាមផ្លូវកំពង់ស្ពឺមក ។

វណ្ណៈ កាលហ្នឹងអត់មានជិះឡានទេ?

ភួតៈ អត់មានទេ ជិះឡានបានមកដល់ត្រពាំងជងខេត្តកំពង់ស្ពឺទេ ក្រោយពីនោះដើរកាត់រហូត ។

វណ្ណៈ ចឹងពូមកតាមផ្លូវឃើញសភាពយ៉ាងម៉េចដែរ?

ភួតៈ វេទនាណាស់ ។

វណ្ណៈ មានមនុស្សស្លាប់ទេ?

ភួតៈ មានស្លាប់ច្រើនណាស់ បើជនពិការការវិញ គេបរឡានទៅប្តូស្នូរគ្រាប់បែក ម្តាយនិងកូនខ្លះដាច់ទឹកស្លាប់ ម្តាយស្លាប់ទៅកូនទៅបៅដោះទៅឃើញអស់ហើយ ចុះដើរមករហូតមកមកដល់ស្រុកបាកានហ្នឹង កាលហ្នឹងពួកខ្ញុំរត់ចេញមកហ្នឹងវៀតណាមមិនទាន់ចូលផង អត់មានជួប មកជួបនៅផ្លូវជាតិលេខ១០នៅប៉ៃលិន ដឹងថាវៃគ្នាទៅបានចាប់បានវៀតណាមបួននាក់ ។

វណ្ណៈ ចឹងពូរត់មកដល់ទល់ដែនវិញនៅឆ្នាំ៧៩ហ្នឹងដែរ?

ភួតៈ បាទ! ៧៩ខែ១ បានខ្ញុំផ្លាស់ពីម៉ាឡៃបានខ្ញុំទៅខាងអន្លង់វែងទៅនៅជាមួយពូកកែវពក ។

វណ្ណៈ ចឹងកាលហ្នឹងពូនៅជាមួយខ្មែរក្រហមដដែល?

ភួតៈ បាទ ។

វណ្ណៈ កាលហ្នឹងនៅម៉ាឡៃបានរយៈប៉ុន្មាន?

ភួតៈ មើលខែ១ មើលខែ៣ទេ ចឹងកាលហ្នឹងឆ្នាំ៨០ ខែ១ទេ បានផ្លាស់ទៅនៅអន្លង់វែងកាលហ្នឹងទៅតាមឡានថៃដឹកទៅដាក់នៅហ្នឹងបណ្តោយហ្នឹងនៅកងពលជាមួយតា ទៀម ។

វណ្ណៈ ចឹងថានៅជាមួយកែវ ពកនោះ?

ភួតៈ បាទ!នៅជាមួយគ្នាហ្នឹង ។

វណ្ណៈ ចឹងអន្លង់វែងកែវ ពក?

ភូតៈ កែវ ពកគាត់នៅខាងនោះទេ តែក្រោមបញ្ជារបស់តា ម៉ុកហ្នឹងឯង ។

វណ្ណៈ ចឹងនៅខាងអន្លង់វែងហ្នឹងមានព្រៃច្រើនដូចនៅខាងម៉ាឡៃដែរ?

ភូតៈ ដូចគ្នានៅស្រុកម៉ាឡៃចឹង ។

វណ្ណៈ ចឹងនៅជាមួយតា ម៉ុកស្រួលជាងនៅជាមួយតា អៀង សារីឬមួយយ៉ាងម៉េច?

ភូតៈ មិនដឹងជាយ៉ាងណាយ៉ាណីវាមិនខុសគ្នាទេ នៅឆ្នាំ១៩៨១ខ្ញុំចុះទៅធ្វើការនៅស្វាយលើ ស្រុកជីក្រែងដល់ឡើងមកវិញឮថាចាប់ប្រធានកងពលមេៗខ្ញុំទៀត ។

វណ្ណៈ ឆ្នាំ៨១ហ្នឹង?

ភូតៈ បាទ! កាលហ្នឹងមានទាស់ទែងគ្នា កងពល៩៨៩ហ្នឹង បានវៃគ្នារវាងខ្មែរក្រហមនិងខ្មែរក្រហមហ្នឹង ។

វណ្ណៈ ឈ្មោះជាមួយពីណាខ្លះ?

ភូតៈ ឈ្មោះមួយកងពលខ្ញុំហ្នឹងហើយ ដែលតា ម៉ុកចាប់មេខ្ញុំ ខ្ញុំមិនយល់ព្រមឲ្យចាប់ ។

វណ្ណៈ កាលហ្នឹងប្រុងចាប់មេឈ្មោះអី?

ភូតៈ ឈ្មោះបង រ៉េត គាត់មកស្លាប់នៅភ្នំស្រួចនេះ អូរស្មាច់នេះ ។

វណ្ណៈ ចឹងកាលហ្នឹងមានចាប់បានទេ?

ភូតៈ ចាប់មិនបានទេ ទី២ឈ្មោះ វែង វ៉ាង ទី៣ឈ្មោះ ផុន ។

វណ្ណៈ ចឹងពូនៅជាមួយតា ម៉ុកដល់ឆ្នាំណា?

ភូតៈ ខ្ញុំនៅដល់ឆ្នាំ៨១ ខែ៧ហ្នឹងឯងដែលខ្ញុំរត់មកខាងប៉ារាវិញ ។

វណ្ណៈ ចឹងពូឈប់នៅជាមួយខ្មែរក្រហមហើយ?

ភូតៈ បាទ!ឈប់នៅហើយ កាលនោះខាងប៉ារាមិនមានជាកងពលអីទេ កាលហ្នឹងទើបតែមានចលនាតស៊ូបន្តិចបន្តួច ។

វណ្ណៈ ចឹងនៅខាងសម្តេចសីហនុ?

ភូតៈ កាលហ្នឹងក៏មិនទាន់ឮឈ្មោះចេញថា ជាសម្តេចឪដែរ កាលនោះគ្រាន់ជាចលនាមួយ ។

វណ្ណៈ ចឹងកាលហ្នឹងពីណាជាប្រធាន?

ភូតៈ កាលនោះឈ្មោះ សា វីធឿន ។

វណ្ណៈ ខាងប៉ារាសម្តេចក្រុមព្រះ?

ភូតៈ កាលនោះមិនទាន់ចេញជាតួស្តេចអីទេ ។

វណ្ណៈ កាលហ្នឹងមានប៉ារាពីរ?

ភួត:	បាទ ។

វណ្ណៈ	កាលហ្នឹងមានខាងសាក់ ស៊ីសាខន លោកតា សឺន សាន?

ភួត:	បាទ! តែកាលនោះគ្រាន់ជាចលនា ពួកខ្ញុំចូលមកក៏មិនទាន់មានដឹងថាសម្ដេចឪដឹកនាំនៅឡើយទេ ។

វណ្ណៈ	ចឹងឆ្នាំណាបានចូលរួមជាចលនាជាមួយខ្មែរក្រហមវ៉ៃវៀតណាមនិងទាហានសាធារណរដ្ឋប្រជាមានិតកម្ពុជា?

ភួត:	កាលនោះប្រហែលជាឆ្នាំ១៩៨៥ ទេ ឆ្នាំ៨២តែមិនដឹងជាខែប៉ុន្មានទេ ។

វណ្ណៈ	កាលនោះវ៉ៃជាមួយយួន?

ភួត:	កាលនោះនៅវ៉ៃជាមួយយួនហ្នឹងឯង ពួកខ្ញុំចូលមកខាងខត្តទឹសខ្វះកំលាំងវ៉ៃចូលអូរស្មាច់ដល់ពួកខ្ញុំមកក៏វ៉ៃយកអូរស្មាច់និងបណ្ដាយ ។

វណ្ណៈ	ចឹងសម្ភារយកមកពីខាងណា?

ភួត:	សម្ភារយកមកតាមរៀងៗខ្លួន ។

វណ្ណៈ	តែប្រទេសណាជាអ្នកជំនួយ?

ភួត:	ខ្ញុំមិនដឹងថាជាប្រទេសណាជំនួយទេ តែឧបករណ៍របស់ចិនតែម្ដង សព្វាវុធគឺចិន ។

វណ្ណៈ	ចឹងនៅពេលដែលកងទ័ពវៀតណាមដកទ័ពចេញនៅឆ្នាំ១៩៨៧ តើចិននៅតែបន្តការជំនួយទៀត នៅពេលដែលខ្មែរវ៉ៃខ្មែរ មានសម្ភារមកពីខាងណាទៀតឬក៏ឈប់ជួយហើយឬយ៉ាងម៉េច?

ភួត:	រឿងឈប់ជួយឬមិនឈប់ជួយនោះ ខ្ញុំមិនសូវជាបានជ្រាបទេរឿងនោះ ប្រហែលជំនួយនៅតែមាន ព្រោះអាវុធដែលប្រើប្រាស់សុទ្ធតែទំនើបដែរ កាលខ្ញុំនៅធ្វើប៉ារានេះឃើញមានរបស់ចិនខ្លះ មានរបស់អាមេរិចកាំងខ្លះដូចជាពួកអឹមសី ឡង់អឹណាស់ ។

វណ្ណៈ	ចឹងពូនៅខាងប៉ារាដល់ផ្ដាច់ខ្លួន?

ភួត:	ខ្ញុំទើបឈប់នៅឆ្នាំ៩៧នេះទេ កាលនៅភ្នំពេញខ្ញុំនៅបន្ទាយតាំងក្រសាំងនៅភ្នំពេញដែរនៅជាមួយញឹក ប៊ុនឆៃ នៅកងពលលេខ៣ ។

វណ្ណៈ	ចឹងឥឡូវពូឈប់ហើយ?

ភួត:	ខ្ញុំឈប់កាលហ្នឹងឯង ខ្ញុំកាលនោះមានឋានៈវរសេនីយទោលដែរ ពាក់សក្តិ៤ ខ្ញុំនៅសល់មេដៃមាស ប្រាក់ពីសម្ដេចឪសម្ដេចក្រុមព្រះក៏នៅដែរ ។

វណ្ណៈ ចឹងពូឈប់ដោយសារអស់កំលាំងនិងការតស៊ូឬមើលឃើញនយោបាយវាមិនល្អឬមួយយ៉ាងម៉េច?

ភួតៈ ខ្ញុំមើលឃើញថានយោបាយមិនល្អ តស៊ូទៅទៀតវាមិនកើត ពីដើមថាវៃបរទេសឈ្លានពាន បន្ទាប់ពីវៃបរទេសឈ្លានពាន ក៏វៃដកអាវុធពីខ្មែរក្រហម បញ្ចប់ពីខ្មែរក្រហមមកថាចប់ហើយ មកខ្មែរគ្នាឯងវៃប្រទូះប្រទូះមើលទៅមិនស្រួល ។

វណ្ណៈ ចឹងកាលបង្កើតចលនាម៉ូលីណាការ សេរីការប៉ារាជាច្រើនហ្នឹងមានការច្រឡំគ្នាវៃគ្នាអីទេ?

ភួតៈ មាន កាលឆ្នាំ៨៣បានប្រមូលខាងម៉ូលីណាការអីហ្នឹង ខ្ញុំនៅបានមួយឆ្នាំបានឃើញលោកតា អិនតាំទៅបង្កើតនៅអូរស្មាច់ កាលហ្នឹងក៏មានព្រះអង្គម្ចាស់ចក្រពង្សមកបង្កើតជាអគ្គសេនាធិការ ហើយបានប្រមូលកងទ័ពទៅគ្រប់ទីសទីទាំងអស់ទៅរៀបជាកងពល ។

វណ្ណៈ បាទ ។

ភួតៈ កាលនោះវាមាន៥កងពល ។

វណ្ណៈ ចឹងកាលហ្នឹងពូមានដែលឃើញទាហានវៀតណាមចាប់បានទាហានប៉ារាអីទេ?

ភួតៈ មិនដែលឃើញ ។

វណ្ណៈ ចឹងខាងនេះមានដែលចាប់បានពួកយួនទេ?

ភួតៈ ចាប់បាន ។

វណ្ណៈ ចាប់បានមានវិធានការយ៉ាងម៉េច?

ភួតៈ ខាងខ្ញុំមិនសូវចាប់បានក្នុងសមរភូមិទេ ច្រើនតែមានរត់ចូលបើរត់ចូលយើងបញ្ជូនទៅតាមសិទ្ធមនុស្សអីគេទៅណាស់ ។

វណ្ណៈ ចឹងមានធ្វើបាបទេ?

ភួតៈ អត់មានធ្វើបាបទេ មានដូចឈ្មោះថៃ មានប្រពន្ធកូនខ្ញុំបញ្ជូនឡើងទៅលើមានក្រុមសិទ្ធមនុស្សគេទទួលយក ។

វណ្ណៈ ចឹងកាលហ្នឹងយួនអីស្លាប់ច្រើនដែរ?

ភួតៈ ស្លាប់ច្រើនកាលវៃនៅជីរំតា ទុំអី ។

វណ្ណៈ ចឹងនៅភូមិស្រុកនេះឆ្នាំ៩៣មានបោះឆ្នោតដែរ?

ភួតៈ បាទ! បានបោះឆ្នោតឆ្នាំ៩៣ខ្ញុំនៅជាទាហាននៅឡើយនៅប្រចាំការ ។

វណ្ណៈ ចឹងបោះឆ្នោតតែប្រជាជនទេ?

ភួតៈ ទាហានក៏មានសិទ្ធបោះឆ្នោតដែរ ។

វណ្ណៈ ចឹងកាលហ្នឹងខាងខ្មែរក្រហមមិនចូលរួមបោះឆ្នោតទេ តែខាងខ្មែរក្រហមបានជួយបោះឆ្នោតឲ្យខាងគណបក្សហ៊្វុនស៊ិនប៉ិចដោយយល់ឃើញបានផ្ចាប់រួមកំលាំងគ្នាវិញ្ញូនមែនទេ ?

ភួតៈ បាទ ។

វណ្ណៈ ដល់ក្រោយមកខាងគណបក្សហ៊្វុនស៊ិនប៉ិចជាប់ទៅមានការថ្នាំងថ្នាក់ចិត្តគ្នាខ្លះដោយសារមិនបានធ្វើតាមកិច្ចសន្យាណាមួយ ចឹងធ្វើឲ្យមានការតតាំងគ្នាទៀតរហូតដល់ឆ្នាំ១៩៩៦ បានផ្តាច់ខ្លួនដូចជានៅខាងម៉ាឡៃចឹង?

ភួតៈ បាទ ។

វណ្ណៈ ចឹងមកដល់ឥឡូវដោយសារតែពូធ្លាប់ឆ្លងកាត់សង្គ្រាមជាច្រើនមកហើយ តើពូយល់ឃើញ យ៉ាងម៉េចដែរ ចំពោះបញ្ហាសង្គ្រាមនេះ?

ភួតៈ បើនិយាយពីការឆ្លងកាត់សង្គ្រាមឃើញថា វាឆ្អែតឆ្អន់អស់ហើយ បើនិយាយពីរឿងច្បាំង ឃើញថារាប់មិនអស់ទេ រាប់ពាន់សមរភូមិទៅហើយ ហើយខ្ញុំត្រូវគ្រាប់១១ដង ហើយ មានអំបែងនៅពេលខ្លួន ឆ្នាំទៅមិញទើបវះយកអំបែងចេញខ្លះ ។

វណ្ណៈ ចឹងពូធ្វើសង្គ្រាមសឹងតែមួយជីវិតហើយ?

ភួតៈ បាទ!ម៉ាភូមិត្រង់នេះមានពីណាតស៊ូយូរដូចខ្ញុំទេ ។

វណ្ណៈ ចឹងកាលឆ្នាំ៨០ជាងមានផ្ទុះធំចឹងទេ?

ភួតៈ កាលហ្នឹងមានផ្ទុះតូចៗតែខ្ញុំលើកផ្ទុះធំមួយទទឹង៨ម៉ែត្របណ្តោយ៩ម៉ែត្រ ការកូនទៅជាប់ លុយកាក់ទេ ខ្ញុំក៏លក់ទៅ ទើបលក់ឆ្នាំទៅមិញ ។

វណ្ណៈ ចឹងប្រជាជននៅកន្លែងហ្នឹងមានរងគ្រោះដោយសារតែសង្គ្រាមដែរ?

ភួតៈ នៅកន្លែងនេះតាំងពីកើតសង្គ្រាមមក ខ្ញុំសួរតាៗមកនៅកន្លែងនេះដោយសារសង្គ្រាមមាន ភ្លើងឆេះភូមិរហូតដល់ទៅ៦៩ដង ។

វណ្ណៈ ចឹងភូមិហ្នឹងឆេះ៦៩ដង?

ភួតៈ បាទ!ឆេះ៦៩ដង ។

វណ្ណៈ ចឹងគិតតាំងពីមានទម្លាក់គ្រាប់បែកមក?

ភួតៈ បាទ!តាំងពីមានការទម្លាក់គ្រាប់បែកមករហូតដល់ឆ្នាំ១៩៩៧ មាន៦៩ដង ។

វណ្ណៈ	ចឹងទោះបីពូផ្លាប់តស៊ូ នៅខាងមុខសម័យខ្មែរក្រហមមិនសូវមានការលំបាកទេ តែនៅក្នុងសម័យខ្មែរក្រហមពូមានមានបាត់បង់បងប្អូនដែរ?

ភូតៈ	មាន ដាច់ពូជប៉ិត ។

វណ្ណៈ	មានប៉ុន្មាននាក់?

ភូតៈ	ពីរនាក់ ម្នាក់នោះដាច់ពូជទាំងអស់សូម្បីតែក្មួយមួយក៏មិនទុក ។

វណ្ណៈ	បងប្អូនបង្កើត?

ភូតៈ	បាទ/បងប្អូនបង្កើត ។

វណ្ណៈ	គាត់ឈ្មោះអីទៅ?

ភូតៈ	ឈ្មោះ ឈុំ ឈឿង ។

វណ្ណៈ	មួយទៀត?

ភូតៈ	ឈុំ ខូង កាលពីដើមគាត់ធ្វើជាទាហានពាក់សក្តិមួយ កាលហ្នឹងជាទាហានលន់ នល់ ហើយគាត់ត្រូវរបួស កាលវិក្នុងភូមិហ្នឹងបាក់ដៃ ដល់សម័យប៉ុល ពតគេឲ្យធ្វើគ្រូបង្រៀនខ្ញុំមិនដែលបាននៅភូមិ តែក្រោយមកឮថា ប៉ុល ពតយកទៅសម្លាប់ចោលដាច់ពូជប៉ិត ។

វណ្ណៈ	ចឹងស្លាប់ជំនាន់ប៉ុល ពត?

ភូតៈ	បាទ ។

វណ្ណៈ	ហើយឆ្នាំណាដែលគេយកទៅសម្លាប់ហ្នឹង?

ភូតៈ	ខ្ញុំមិនបានដឹងទេ ខ្ញុំមិនបានសួរនាំផង ខ្ញុំមិនដែលបានចូលស្រុកទេ ហើយបងមួយទៀតគាត់ចេញទៅ គាត់ជាមូលដ្ឋានចាស់ ។

វណ្ណៈ	បាទ ។

ភូតៈ	ដល់មូលដ្ឋានចាស់ទៅមេធំៗគេប្រើឲ្យគាត់កាន់ខាងពាណិជ្ជកម្មស្រុកថ្មពួក សម័យប៉ុល ពត ហ្នឹងឯងតាមខ្ញុំដឹង ។

វណ្ណៈ	បាទ ។

ភូតៈ	ដល់គេចាប់ចៅហ្វាយស្រុកចៅហ្វាយខេត្តទៅ ក៏ចាប់ដោយទាំងគាត់ទៅបាត់ទៅ ។

វណ្ណៈ	តែឪពុកពូស្លាប់ក្រោយ៧៩ទេ ម្តាយពូស្លាប់តាំងពីសង្គមចាស់នោះទេ?

ភូតៈ	បាទ ។

វណ្ណៈ	ចឹងមានតែបងប្អូនពីរនាក់ទេដែលរងគ្រោះនៅសម័យបីឆ្នាំ?

ភួតៈ បាទ!បងប្អូនខ្ញុំ៦នាក់ស្លាប់អស់ពីរ នៅសល់បួននាក់ ។

វណ្ណៈ សាច់រឿងពូល្អតែវាយប់ហើយ ។

ភួតៈ បាទ ។

វណ្ណៈ ចឹងខ្ញុំចង់សួរទាក់ទងរឿងតុលាការវិញ ដោយសាររឿងរ៉ាវនេះវាកន្លងផុតទៅហើយ តែអំពើឃោរឃៅនៅប្រទេសយើងបានរំលោភច្បាប់អន្តរជាតិ ចឹងហើយបានជាសព្វថ្ងៃនេះមានតុលាការអន្តរជាតិនិងតុលាការខ្មែរយើងសហការគ្នាដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលបានធ្វើឲ្យប្រជាជនស្លាប់ជាងមួយលាននាក់ ។

ភួតៈ បាទ ។

វណ្ណៈ ចឹងរឿងតុលាការហ្នឹងពូមានការគាំទ្រដែរឬមិនមានការគាំទ្រទេ រឿងតុលាការហ្នឹង?

ភួតៈ បើតាមយោបល់ខ្ញុំ ខ្ញុំគាំទ្រ១០០ភាគ១០០តែម្តង ព្រោះថាឪពុកខ្ញុំក៏ធ្វើជាទាហានក្នុងសម័យនោះដែរ គេថាជាតិមិនជាតិយ៉ាងម៉េចទេ ខ្ញុំនៅតែជាយដែនមិនដឹងជាឪពុកម្តាយបងប្អូនស្លាប់ដោយវេទនាយ៉ាងណា ដល់ពេលដែលខ្ញុំបានមកឃើញនូវទិដ្ឋភាពស្រុកស្រែក្នុងសម័យសង្គ្រាមនេះ ខ្ញុំស្អប់ខ្ពើមជាទីបំផុត ដល់មានតុលាការកាត់ទោសចឹង ខ្ញុំមានសេចក្តីត្រេកអរច្រើន ។

វណ្ណៈ បាទ ។

ភួតៈ កុំឲ្យប្រទេសគេដទៃយកគំរូតាម ។

វណ្ណៈ ចឹងពូគិតថាមានប្រយោជន៍ទេ តុលាការហ្នឹង?

ភួតៈ រឿងមានប្រយោជន៍ឬមិនមានប្រយោជន៍ខ្ញុំក៏មិនសូវបានដឹងដោយជ្រៅជ្រះដែរ ខ្ញុំគិតថាវាអាចមានប្រយោជន៍មួយសំគាល់ឃើញថា ខ្មែរយើងតៗទៅក្រោយហ្នឹងកុំឲ្យមេដឹកនាំធ្វើចឹងតទៅទៀត ។

វណ្ណៈ បាទ ។

ភួតៈ រឿងមានប្រយោជន៍សម្រាប់ជាតិយ៉ាងណាខ្ញុំមិនដឹងទេ ។

វណ្ណៈ បើអ្នកដឹកនាំធ្វើឲ្យប្រជាជនស្លាប់ច្រើន ទោះបីយើងមានវ័យចំណាស់បែបណាក៏ដោយបើតាមផ្លូវច្បាប់យើងមិនបានរួចខ្លួនទេ?

ភួតៈ បាទ ។

វណ្ណៈ ចឹងខ្ញុំអរគុណពូច្រើនហើយ ។

ភួតៈ បាទ ។

វណ្ណៈ ចឹងពូមានយោបល់អីបន្ថែមទៀតទេ?

ភ្នួតៈ ខ្ញុំដូចជាគ្មានយោបល់អីបន្ថែមទៀតទេ សូមតែឲ្យមេដឹកនាំសព្វថ្ងៃជួយមើលរាស្ត្រផង ហើយសព្វថ្ងៃបានបង្កើតជារបបប្រជាធិបតេយ្យហើយ ។

វណ្ណៈ បាទ ។

ភ្នួតៈ ដល់ពេលរាស្ត្របោះឆ្នោតជូនទៅហើយ លោកដែលបានអំណាចគឺសុំមើលរាស្ត្រផងទោះបីជារាស្ត្រមានកខុសឆ្គងយ៉ាងណា កុំឲ្យកើតមានដូចជាខុសដៃយកដៃ ខុសជើងយកជើង សូមទាញសេចក្ដីពិចារណាសិន ។

វណ្ណៈ បាទ ។

ភ្នួតៈ ព្រោះកន្លងមកអាចមានទៅហើយ ចឹងសូមតែប៉ុណ្ណឹងទេ ។

វណ្ណៈ បាទ!ចឹងខ្ញុំអរគុណពូ ។

ភ្នួតៈ បាទ ។

«ចប់»